# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...០៧...សរណន

# សារាចរណែនាំ

## ស្តីពី

## ការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា

ដោយអនុវត្តតាមផែនការជាតិនៃការអប់រំសំរាប់ទាំងអស់គ្នា ដែលប្រកាសផ្សព្វផ្សាយអនុវត្តនាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣ និងផ្អែកលើព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការកំនត់យកថ្ងៃទី ៨ ខែ កញ្ញា រៀងរាល់ឆ្នាំ ជាទិវាអក្ខរកម្មជាតិ និងដើម្បីបំផុស ឃោសនា ផ្សព្វផ្សាយ បង្កើនការយកចិត្តទុកដាក់ជួយឧបត្ថម្ភគាំទ្រ និង លើកទឹកចិត្តដល់ចលនាអក្ខរកម្មអោយបានខ្លាំងក្លាថែមទៀតនោះ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង អោយរៀបចំប្រារព្ធទិវាអក្ខរកម្មជាតិ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៤ ក្រោមប្រធានបទ **"អក្ខរកម្ម ជាគន្លឹះនៃការអភិវឌ្ឍ"** ដូចខាងក្រោម :

១. ក្រសួងអប់រំ យុវជន និង កីឡា ត្រូវរៀបចំពិធីមីទិញថ្នាក់ជាតិ ជានិមិត្តរូបនៅតាមខេត្ត ក្រុងណាមួយ ដើម្បីផ្សព្វផ្សាយលទ្ធផលអក្ខរកម្មឆ្នាំកន្លងមក និង ប្រកាសអំពីផែនការនៃការអនុវត្តផែនការជាតិអប់រំសំរាប់ទាំងអស់គ្នានៅទូទាំងប្រទេសទៅថ្ងៃមុខ ។

២. ក្រសួង មន្ទីរ និង អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចាត់ចែងរៀបចំបិទបដា ពាក្យស្លោកដូចជូនភ្ជាប់នៅតាមអង្គភាពរដ្ឋ ទីប្រជុំជន ដងផ្លូវសាធារណៈ ចាប់ពីថ្ងៃទី ៧ ដល់ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៤។

៣. ក្រសួងធម្មការ និង កិច្ចការសាសនា ត្រូវទូលសុំព្រះសង្ឃ បព្វជិតសាសនាដទៃទៀត និង ណែនាំគណៈកម្មការវត្តគ្រប់ជាន់ថ្នាក់ និង សាវ័ក អោយចូលរួមដល់ការងារអក្ខរកម្ម ។

៤. ក្រសួងព័ត៌មានត្រូវរៀបចំជាកម្មវិធីសិល្បៈ បទអត្ថាធិប្បាយ បទយកការណ៍ ស្តីពីការងារអប់រំក្រៅប្រព័ន្ធនៅកម្ពុជា ផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍ ។

៥. អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវចាត់ចែងរៀបចំ :

ក-ធ្វើមីទិញ ឬ ប្រជុំហែក្បួនដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងការឧបត្ថម្ភគាំទ្រ និង លើកទឹកចិត្តដល់ចលនាអក្ខរកម្ម ដែលជាកូនសោ ក្នុងការអភិវឌ្ឍខ្លួនឯង គ្រួសារ សហគមន៍ និង ប្រទេសជាតិទាំងមូល ។

ខ-សហការជាមួយបណ្តាអង្គការនានា ដែលធ្វើសកម្មភាពផ្នែកអប់រំក្រៅប្រព័ន្ធ ដើម្បីរៀបចំជាពិពណ៌ បង្ហាញ អំពីសកម្មភាព និង លទ្ធផលនៃការងារអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំកន្លងមក ។

គ- បំផុសចលនា និង ធ្វើការប្រឡងជ្រើសរើសសិស្សអក្ខរកម្មពូកែតាមលក្ខខ័ណ្ឌដូចខាងក្រោម :

-ចំពោះទីកន្លែងដែលមានថ្នាក់អក្ខរកម្ម ត្រូវចាត់ចែងរៀបចំប្រឡង ហើយបេក្ខជនដែលទទួលបានពិន្ទុល្អ ក្នុងការប្រឡងនឹងត្រូវបានជូនរង្វាន់លើកទឹកចិត្តតាមលទ្ធភាពរបស់ខេត្ត ក្រុង និង មូលដ្ឋាននីមួយៗ ។

-ចំពោះទីកន្លែងដែលពុំមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងរៀបចំអោយមន្ត្រីជំនាញចុះឃោសនាអំពី សារៈសំខាន់នៃការរៀនសូត្រ ដែលជាមូលដ្ឋានគ្រឹះនៃការអប់រំ ។

ឃ-ចាត់ចែងឃោសនា អំពាវនាវដល់អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន និង សាធារណជន ទូទៅអោយ ចូលរួមជួយគាំទ្រដល់សកម្មភាពទិវានេះក្នុងតំបន់រៀងៗខ្លួន ។

៦. គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នានៅគ្រប់លំដាប់ថ្នាក់ ត្រូវប្រជុំរៀនសូត្រអំពីគោលនយោបាយនៃការងារ អប់រំក្រៅប្រព័ន្ធ និង ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ព្រមទាំងបូកសរុបលទ្ធផលនៃការងារអប់រំក្រៅ ប្រព័ន្ធតាមសភាពជាក់ស្តែង តាមឋានានុក្រមនីមួយៗ ។

៧. អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន និង សាធារណជនសូមចូលរួម ជួយសហការគាំទ្រទិវានេះ អោយបានខ្លាំងក្លានៅតាមទីកន្លែង និង តាមលទ្ធភាពរបស់ខ្លួន ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នាត្រូវផ្សព្វផ្សាយ និង រៀបចំណែនាំព្រមទាំងអនុវត្តន៏សារាចរនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ រួចហើយធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំពិធីនេះ ផ្ញើមកក្រសួងអប់រំ យុវជន និង កីឡា ដើម្បីបូកសរុបជូនគណៈរដ្ឋមន្ត្រីអោយបានមុនដំណាច់ខែ កញ្ញា ឆ្នាំ ២០០៤ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័ននានា
-គ្រប់សាលាខេត្ត ក្រុង
-កាលប្បវត្តិ -ឯកសារ

## ពាក្យស្លោក

១. ជយោ ! ព្រះរាជាណាចក្រកម្ពុជា

២. ជាតិ សាសនា ព្រះមហាក្សត្រ

៣. អបអរសាទរទិវាអក្ខរកម្មជាតិ ៨ កញ្ញា

៤. រៀនហើយ រៀនទៀត រៀនពេញមួយជីវិត

៥. អប់រំសំរាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ

៦. រៀនដើម្បីអភិវឌ្ឍខ្លួនឯង គ្រួសារ និងសង្គមជាតិ

៧. អក្ខរកម្មជាពន្លឺនៃសុភមង្គល

៨. អក្ខរកម្ម គឺជាគន្លឹះនៃការអភិវឌ្ឍន៍

៩. អក្ខរកម្មរួមចំណែកកាត់បន្ថយភាពក្រីក្រ

១០. អក្ខរកម្មទប់ស្កាត់អេដស៍

១១. អក្ខរកម្មទប់ស្កាត់ការកេងប្រវ័ញ្ចពលកម្មកុមារ

១២. អក្ខរកម្មទប់ស្កាត់ការប្រើគ្រឿងញៀន

១៣. អក្ខរកម្ម ជាមធ្យោបាយបំបាត់អំពើហឹង្សា

១៤. មានអក្ខរកម្ម មានចំណេះដឹង មានការអភិវឌ្ឍន៍

១៥. អក្ខរកម្មជាគន្លឹះសំរេចការអប់រំសំរាប់ទាំងអស់គ្នា

១៦. អក្ខរកម្មជាមូលដ្ឋាននៃការសិក្សាពេញមួយជីវិត

១៧. អក្ខរកម្ម គឺជាគ្រឹះនៃចំណេះដឹង

១៨. អក្ខរកម្មជាគ្រឹះនៃការអប់រំ